


# សេចក្តីថ្លែងការណ៍រួម

ពីអ្នករស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទដែលទាក់ទងនឹងជម្លោះនៅអាស៊ី

**កម្មវិធី៖ ការផ្លាស់ប្តូរអ្នករស់រានមានជីវិតក្នុងតំបន់អាស៊ី**

**ថ្ងៃទី ១៨-២០ ខែមិថុនា ឆ្នាំ២០២៥**

**បាងកក ប្រទេសថៃ**

*With the support of*

dr. Denis Mukwege Foundation

GLOBAL SURVIVORS FUND
FOR AND WITH SURVIVORS OF CONFLICT-RELATED SEXUAL VIOLENCE

យើងជាអ្នករស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទទាក់ទងនឹងជម្លោះពីប្រទេសកម្ពុជា នេប៉ាល់ មីយ៉ាន់ម៉ា និងទីម័រខាងកើត បានមកជួបគ្នានៅក្នុងព្រឹត្តិការណ៍ «Asia Regional Survivors Exchange» ដែលរៀបចំដោយ **Global Survivors Fund** និង **Mukwege Foundation** នៅថ្ងៃទី 19-20 ខែមិថុនា ឆ្នាំ 2025 ដើម្បីចែករំលែកបទពិសោធន៍របស់យើង រៀនពីគ្នាទៅវិញទៅមក និងកំណត់អាទិភាពទូទៅសម្រាប់អ្នករស់រានមានជីវិតនៅទូទាំងតំបន់។

សេចក្តីថ្លែងការណ៍នេះចេញមកពីការពិភាក្សារបស់យើង ឆ្លុះបញ្ចាំងពីអាទិភាពរបស់យើង និងរៀបរាប់ពីអ្វីដែលយើងជឿថាមានសារៈសំខាន់សម្រាប់ការឆ្លើយតបដែលផ្តោតលើអ្នករស់រានមានជីវិតចំពោះអំពើហិង្សាផ្លូវភេទដែលទាក់ទងនឹងជម្លោះ។

**តម្រូវការរួមរបស់យើង៖**

1. **ផ្តល់កន្លែងសុវត្ថិភាពសម្រាប់អ្នករស់រានមានជីវិត**ដើម្បីបង្កើតទំនាក់ទំនង ការព្យាបាលផ្លូវចិត្ត គាំទ្រគ្នាទៅវិញទៅមក និងធ្វើការជាមួយគ្នា។

2. **ជួយសម្រួលដល់ការទទួលបានការគាំទ្រជារួមសម្រាប់អ្នករស់រានមានជីវិត** រួមទាំងការគាំទ្រផ្នែកវេជ្ជសាស្ត្រ ផ្លូវចិត្ត ផ្លូវច្បាប់ និងការគាំទ្រសេដ្ឋកិច្ចសង្គម (ដូចជាហិរញ្ញវត្ថុ លំនៅដ្ឋាន ការអប់រំ ជីវភាពរស់នៅ) តាមរយៈកម្មវិធីជំនួយ ឬសំណង ព្រមទាំងជំនួយសង្គ្រោះបន្ទាន់ រួមទាំងទីជម្រកសុវត្ថិភាព និងការផ្លាស់ទីលំនៅនៅពេលពាក់ព័ន្ធ។

3. **លើកកម្ពស់ការយល់ដឹងអំពីមូលហេតុ និងផលវិបាកនៃអំពើហិង្សាផ្លូវភេទដែលទាក់ទងនឹងជម្លោះលើអ្នករស់រានមានជីវិត** ដើម្បីប្រយុទ្ធប្រឆាំងនឹងការមាក់ងាយ និងធានាសុវត្ថិភាពរបស់ពួកគេ។

4. **តស៊ូមតិដើម្បីគណនេយ្យភាព និងយុត្តិធម៌ រួមទាំងសំណងនៅគ្រប់កម្រិត** (ក្នុងស្រុក ជាតិ តំបន់ និងអន្តរជាតិ)។

ការទាមទារទាំងនេះមានមូលដ្ឋាននៅក្នុងបទពិសោធន៍ជីវិតរបស់យើង និងឆ្លុះបញ្ចាំងពីអាទិភាពរួមគ្នារបស់យើងក្នុងនាមជាអ្នករស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទដែលទាក់ទងនឹងជម្លោះនៅទូទាំងអាស៊ី។ យើងសូមអំពាវនាវដល់តួអង្គរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធទាំងអស់ចាត់វិធានការប្រកបដោយអត្ថន័យ ក្នុងការគាំទ្រដល់អ្នកនៅរស់រានមានជីវិត។

*With the support of*